ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ: [illegible]

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រង ឈាម មេជីវិត ខួរឆ្អឹង និងកោសិកាដើមរបស់មនុស្ស

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៦/០១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំ កោសិកា ជាលិកា និងសរីរាង្គមនុស្ស

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីព្រះមុនីវង្ស ... (១២២៥) ភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការគ្រប់គ្រងលើការប្រើប្រាស់ ឈាម មេជីវិត (ញីឬឈ្មោល) និងកោសិកាដើមរបស់មនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២
## ការគ្រប់គ្រងលើការបរិច្ចាគ និងប្រើប្រាស់ឈាម

**ប្រការ២.-**

ការគ្រប់គ្រងលើការបរិច្ចាគឈាម គឺដើម្បីធានាសុខភាព និងសុវត្ថិភាពរបស់អ្នកបរិច្ចាគឈាម និងអ្នកជំងឺដែលទទួលឈាម ព្រមទាំងធានាការផ្គត់ផ្គង់ឈាម និងសមាសធាតុរបស់ឈាម ឲ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការឈាមសម្រាប់សង្គ្រោះជីវិតអ្នកជំងឺ។

**ប្រការ៣.-**

ការបរិច្ចាគឈាម ត្រូវធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្ត មិនធ្វើពាណិជ្ជកម្ម ដោយគ្មានការរើសអើង មិនប្រកាន់ជាតិសាសន៍ឬសាសនា ។

អ្នកបរិច្ចាគឈាមត្រូវមានអាយុពី ១៨ឆ្នាំ ដល់ ៦០ឆ្នាំ និងមានសុខភាពល្អ។

**ប្រការ៤.-**

រាល់ការពិនិត្យសុខភាពដល់អ្នកបរិច្ចាគមុនការបរិច្ចាគឈាម ការវិភាគឈាម ត្រូវទទួលខុសត្រូវដោយបុគ្គលិកពេទ្យជំនាញ។

មន្ត្រីដែលជាប់ពាក់ព័ន្ធទាំងអស់ត្រូវទទួលខុសត្រូវក្នុងការអប់រំប្រជាជនអំពីគោលការណ៍នៃការបរិច្ចាគឈាមដោយស្ម័គ្រចិត្តជាសាកលនេះឲ្យបានទូលំទូលាយ។

**ប្រការ៥.-**

ចន្លោះពេលពីម្តងទៅម្តងនៃការបរិច្ចាគឈាម ឬការបរិច្ចាគសមាសធាតុផ្សេងៗរបស់ឈាម និងបរិមាណដែលអាចយកបាន ត្រូវកំណត់ទៅតាម ភេទ និងទម្ងន់ខ្លួនរបស់អ្នកបរិច្ចាគ ហើយត្រូវអនុវត្តតាមគោលការណ៍ណែនាំថ្នាក់ជាតិដែលត្រូវបានអនុមត័ដោយក្រសួងសុខាភិបាល។

**ប្រការ៦.-**

ការយកប្លាស្មា ឬសមាសធាតុរបស់ឈាម ក្នុងគោលបំណងព្យាបាលអ្នកជំងឺត្រូវគោរពតាមលក្ខណៈបច្ចេកទេសវេជ្ជសាស្ត្រ តាមការណែនាំរបស់ក្រសួងសុខាភិបាល ។

**ប្រការ៧.-**

មជ្ឈមណ្ឌលជាតិផ្តល់ឈាមរបស់ក្រសួងសុខាភិបាល មានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធគុណភាពលើគ្រប់ដំណើរការនៃការបរិច្ចាគឈាម ការវិភាគឈាម ការរំលែកឈាម ការរក្សាទុកឈាម និងការបែងចែកឈាមដល់គ្រប់មន្ទីរពេទ្យរដ្ឋ និងមន្ទីរព្យាបាលឯកជនទាំងអស់។

ក្រសួងសុខាភិបាលរក្សាសិទ្ធគ្រប់យ៉ាងក្នុងការបញ្ឈប់រាល់សកម្មភាពរបស់បុគ្គល ឬគ្រឹះស្ថានទាំងឡាយណា ដែលផ្តល់សេវាកម្មផ្គត់ផ្គង់ឈាមដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល។

**ប្រការ៨.-**

រាល់ការសម្រេចចិត្តធ្វើការចាក់បញ្ចូលឈាម ជាការទទួលខុសត្រូវរបស់គ្រូពេទ្យព្យាបាលនៅគ្រប់មន្ទីរពេទ្យទៅតាមតម្រូវការនៃការព្យាបាល និងគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និងមិនត្រូវធ្វើឡើងក្នុងគោលបំណងបែបពាណិជ្ជកម្មឡើយ។

## ជំពូកទី៣
## ការគ្រប់គ្រង លើការបរិច្ចាគនិងប្រើប្រាស់ កោសិកាមេជីវិត (ញីឬឈ្មោល)

**ប្រការ៩.-**

ការគ្រប់គ្រងលើការបរិច្ចាគកោសិកាមេជីវិត(ញីឬឈ្មោល)គឺដើម្បីធ្វើឲ្យការប្រើប្រាស់កោសិកាមេជីវិតប្រកប ដោយក្រមសីលធម៌ និងដើម្បីទប់ស្កាត់ការឆ្លងមេរោគតាមមេជីវិតនិងជំងឺតពូជ។

### ផ្នែកទី១
### អ្នកបរិច្ចាគកោសិកាមេជីវិត

**ប្រការ១០.-**

ការបរិច្ចាគមេជីវិត រាប់បញ្ចូលការដកហូតកោសិកាមេជីវិតឈ្មោល កោសិកាមេជីវិតញី និងអំប្រីយ៉ុ។

អ្នកបរិច្ចាគមេជីវិត ត្រូវៈ

-ធ្វើការបរិច្ចាគដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត

-មានសុខភាពល្អ និងពុំមានជំងឺតពូជ ឬជំងឺដែលអាចឆ្លងតាមកោសិកាមេជីវិត

-មានអាយុយ៉ាងតិច១៨ឆ្នាំ។

ការបរិច្ចាគមេជីវិតដែលមានលក្ខណៈពាណិជ្ជកម្ម ត្រូវហាមឃាត់ដាច់ខាត។

## ផ្នែកទី២
## អ្នកទទួលកោសិកាមេជីវិត

**ប្រការ១១._**

អ្នកទទួលកោសិកាមេជីវិត ឬអ្នកទទួលអំប្រីយ៉ូដែលបានកើតចេញពីការបង្កាត់មេជីវិតញីជាមួយឈ្មោល ត្រូវចាត់ទុកជាអ្នកទទួលមេជីវិត។

អ្នកទទួលកោសិកាមេជីវិតត្រូវបានរាប់បញ្ចូលទាំងអ្នកដែលទទួលមេជីវិតឬអំប្រីយ៉ូ ដោយធ្វើការពរពោះដោយខ្លួនឯង។

**ប្រការ១២._**

រាល់ការពរពោះជំនួស ដែលជាសេវាមួយនៃកញ្ចប់សេវានានានៃការជួយឲ្យមានកូនតាមបែបបច្ចេកទេសវិទ្យាសាស្ត្រ( Assisted Reproductive Technology ) ត្រូវហាមឃាត់ដាច់ខាត។

## ផ្នែកទី៣
## ការគ្រប់គ្រងលើគ្រឹះស្ថានប្រើប្រាស់កោសិកាមេជីវិត ( ញីឬឈ្មោល )

**ប្រការ១៣._**

មេជីវិតអាចអនុញ្ញាតឲ្យយកទៅប្រើប្រាស់ដើម្បីបង្កើតជាកូនមនុស្សតែប៉ុណ្ណោះ( មិនត្រូវបានអនុញ្ញាតឱ្យបង្កើតជាអំប្រីយ៉ូ (embryo) សម្រាប់ការសិក្សាណាមួយឡើយ។

អំប្រីយ៉ូដែលនៅសល់ពីការបង្កាត់ហើយត្រូវបានបោះបង់ចោល អាចអនុញ្ញាតឲ្យយកទៅធ្វើការសិក្សាស្រាវជ្រាវបាន ប្រសិនបើទទួលបានការយល់ព្រមពីគណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស។

**ប្រការ១៤._**

គ្រឹះស្ថានដែលមានសេវាដកហូតមេជីវិតឬរក្សាទុកមេជីវិត ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ១៥._**

គ្រូពេទ្យឯកទេសដែលផ្តល់សេវាកម្មព្យាបាលឲ្យមានកូនតាមបែបបច្ចេកទេសវិទ្យាសាស្ត្រ (Assisted Reproductive Technology )ត្រូវតែមានការទទួលស្គាល់ពីក្រសួងសុខាភិបាល និងត្រូវអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាធរមានសម្រាប់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។

**ប្រការ១៦.-**

គ្រឹះស្ថានដែលមានផ្ដល់សេវាជួយឲ្យមានកូនតាមបែបបច្ចេកទេសវិទ្យាសាស្ត្រ (Assisted Reproductive Technology) ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ១៧.-**

មិនអនុញ្ញាតឱ្យបង្កើតអំប្រីយ៉ុងសម្រាប់គោលបំណងពាណិជ្ជកម្ម ឬគោលបំណងអ្វីផ្សេងពីការបង្កើតអំប្រីយ៉ុងសម្រាប់ជួយគូស្វាមីភរិយាស្របច្បាប់ឲ្យមានកូនឡើយ ។

## ជំពូកទី៤
## ការគ្រប់គ្រង និងប្រើប្រាស់ខួរឆ្អឹងនិងកោសិកាដើមរបស់មនុស្ស

**ប្រការ១៨.-**

គ្រឹះស្ថានសុខភាពដែលមានសេវារក្សាទុកកោសិកាដើមរបស់មនុស្ស ការប្រើប្រាស់កោសិកាដើមរបស់មនុស្ស ការដកហូតខួរឆ្អឹងឬធ្វើការបណ្ដុះខួរឆ្អឹង ត្រូវមានការយល់ព្រមពីក្រសួងសុខាភិបាល ។

**ប្រការ១៩.-**

ការបរិច្ចាគ កោសិកាខួរឆ្អឹងឬកោសិកាដើមគ្រប់ប្រភេទ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងមិនមានលក្ខណៈពាណិជ្ជកម្ម។

**ប្រការ២០.-**

រាល់ការប្រមូលកោសិកាដើមរបស់មនុស្ស ត្រូវសុំការយល់ព្រមពីបុគ្គល ឬអាណាព្យាបាលជាមុនដោយមានជាលាយលក្ខអក្សរ។

**ប្រការ២១.-**

ការប្រើប្រាស់កោសិកាដើមគ្រប់ប្រភេទសម្រាប់ការស្រាវជ្រាវ ត្រូវសុំការយល់ព្រមពីគណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ២២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២៣.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពសុខាភិបាលថ្នាក់កណ្តាល រាជធានី ខេត្តទាំងអស់ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- សាលារាជធានី-ខេត្ត
- ដូចប្រការ២៣
- ឯកសារ-កាលប្បវត្តិ